**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១០-១៥០ ប្រ.ក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើ
## គំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាមានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមការអនុម័តិរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើឯកភាពគ្នានៅក្នុងប្រព័ន្ធធនាគារនូវគំរូបញ្ជាទូទាត់ សម្រាប់ការទូទាត់សងប្រាក់ជាលាយលក្ខណ៍អក្សរឬជាអេឡិចត្រូនិក ដែលមានទម្រង់ជាការផ្ទេរឥណទាន ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

បញ្ជាទូទាត់នេះនឹងត្រូវបានប្រើ ដើម្បីផ្ទេរប្រាក់ពីគណនីរបស់អ្នកសងប្រាក់ទៅគណនីរបស់អ្នកទទួលប្រាក់ ដែលគណនីទាំងនេះអាចមាន ឬមិនមាននៅក្នុងធនាគារ ឬសាខាធនាគារជាមួយគ្នា ។

**ប្រការ ២.-**

បញ្ជាទូទាត់ត្រូវបានប្រើជាឧបករណ៍ស្របច្បាប់ អនុលោមតាមមាត្រា ១៩៩, ២០០, ២០១ និង ២០២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។ បញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានត្រូវបានរៀបចំឱ្យមានលក្ខណៈស្តង់ដារច្បាស់លាស់ និងគ្រប់គ្រាន់ អំពីទម្រង់ ទិន្នន័យ និងព័ត៌មាន ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ ។

**ប្រការ ៣.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១០

**ទេសាភិបាល**

ជា_ចាន់តូ

**កន្លែងទទួល៖**
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ...........................................................

# ឧបសម្ព័ន្ធ

ប្រកាសលេខ ធ៩.០១០.១៥០ ប្រក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

## លក្ខណៈស្តង់ដារនៃបញ្ជាទូទាត់

ទម្រង់ ទិន្នន័យ និងព័ត៌មាន ដែលត្រូវបំពេញនៅក្នុងបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន ជាលាយលក្ខណ៍អក្សរ និងអេឡិចត្រូនិក ត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋានបី ដូចខាងក្រោមៈ

- SWIFT
- សារប័ណ្ណ(Card Message)
- មូលប្បទានប័ត្រស្តង់ដារ ដូចមានចែងនៅក្នុងប្រកាសលេខ ធ៩-០៨-១៨៦ និងឧបសម្ព័ន្ធនៃប្រកាសនេះ។

### ១-តារាង ទិន្នន័យ និងព័ត៌មាននៃការផ្ទេរឥណទាន

| ឈ្មោះខ្លឹមសារ | ទម្រង់ខ្លឹមសារ | ការពន្យល់ |
|---|---|---|
| លេខកូដនៃប្រភេទនៃការទូទាត់សងប្រាក់ | ៦ ខ្ទង់ | លេខកូដតំណាងឱ្យ "ការផ្ទេរឥណទាន" (ជាកាតព្វកិច្ច) |
| កាលបរិច្ឆេទ | ៨ ខ្ទង់ | ថ្ងៃ - ខែ - ឆ្នាំ (00-00-0000) (ជាកាតព្វកិច្ច) |
| លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់ | ៦ ខ្ទង់ | ៣ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច) |
| លេខកូដផ្ទៀងផ្ទាត់ | ១ ខ្ទង់ | សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណធនាគារសងប្រាក់ (ជាកាតព្វកិច្ច) |
| លេខគណនីអ្នកសងប្រាក់ | ១២ ខ្ទង់ | ១២ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

| | | |
|---|---|---|
| ឈ្មោះអ្នកសងប្រាក់ | ៣៥ អក្សរ និង/ឬលេខ | (ជាកាតព្វកិច្ច) |
| អត្ថន័យយោងរបស់អ្នកសងប្រាក់ | ៣០ អក្សរ និង/ឬលេខ | (ជាជម្រើស) |
| ចំនួនប្រាក់ | ១៥ ខ្ទង់ | ១៥ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| លេខកូដរូបិយប័ណ្ណ | ៣ ខ្ទង់ | ៣ខ្ទង់តំណាងឱ្យរូបិយប័ណ្ណ ឧទាហរណ៍ KHR ឬ USD (ជាកាតព្វកិច្ច) |
| លេខកូដសុវត្ថិភាព | ១៨ ខ្ទង់ | តំណាងឱ្យលេខកូដសម្រាប់ផ្ទៀងផ្ទាត់ប្រតិបត្តិការ (ម៉ាស៊ីនគណនាដោយស្វ័យប្រវត្តិ) |
| លេខសម្គាល់អត្តសញ្ញាណធនាគារទទួលប្រាក់ | ៦ ខ្ទង់ | ៣ខ្ទង់ដំបូង ជាលេខអត្តសញ្ញាណធនាគារ ៣ខ្ទង់បន្ទាប់ ជាលេខអត្តសញ្ញាណទីស្នាក់ការកណ្តាល ឬសាខា (ជាកាតព្វកិច្ច) |
| លេខកូដផ្ទៀងផ្ទាត់ | ១ ខ្ទង់ | សម្រាប់ផ្ទៀងផ្ទាត់លេខសម្គាល់អត្តសញ្ញាណធនាគារទទួលប្រាក់ (ជាកាតព្វកិច្ច) |
| លេខគណនីរបស់អ្នកទទួលប្រាក់ | ១២ ខ្ទង់ | ១២ខ្ទង់ ឬបើតិចជាងត្រូវបំពេញខ្ទង់ជាប់គ្នាជាបន្តបន្ទាប់ (ជាកាតព្វកិច្ច) |
| ឈ្មោះអ្នកទទួលប្រាក់ | ៣៥ អក្សរ និង/ឬលេខ | (ជាកាតព្វកិច្ច) |
| អត្ថន័យយោងរបស់អ្នកទទួលប្រាក់ | ៣០អក្សរ និង/ឬលេខ | (ជាជម្រើស) |

## ២- ទម្រង់និងរូបភាព នៃបញ្ជាទូទាត់

ឡូហ្គូ
ធនាគារ

**ការផ្ទេរឥណទាន**

កាលបរិច្ឆេទ : ☐☐☐☐☐☐☐☐

ប្រភពនៃប្រាក់ផ្ទេរ: សាច់ប្រាក់ ☐ ផ្ទេរពីគណនី : ☐

លេខកូដនៃប្រភេទនៃការទូទាត់សងប្រាក់: ☐☐☐☐☐☐

ឈ្មោះអ្នកសងប្រាក់: ☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐

លេខអត្តសញ្ញាណធនាគារសងប្រាក់: ☐☐☐☐☐☐

លេខគណនីអ្នកសងប្រាក់: ☐☐☐☐☐☐☐☐☐☐☐☐

អត្ថន័យយោងរបស់អ្នកសងប្រាក់: ☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐

ចំនួនប្រាក់: ☐☐☐☐☐☐☐☐☐☐☐☐☐☐☐

លេខកូដរូបិយប័ណ្ណ : ☐☐☐

ឈ្មោះអ្នកទទួលប្រាក់: ☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐

លេខអត្តសញ្ញាណធនាគារទទួលប្រាក់: ☐☐☐☐☐☐

លេខគណនីអ្នកទទួលប្រាក់: ☐☐☐☐☐☐☐☐☐☐☐☐

អត្ថន័យយោងរបស់អ្នកទទួលប្រាក់: ☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐

ហត្ថលេខាអ្នកសងប្រាក់ ហត្ថលេខារបស់ភ្នាក់ងារ

........................................ ........................................